ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ន១៤.៤៣៣.០០៧.ប្រកាសព័ត៌មាន

*ថ្ងៃចន្ទ ១២រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ការចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការក្នុងផ្នែកផ្សេងៗនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ រវាង ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលរវ៉ាន់ដា

នៅថ្ងៃសុក្រ ៩រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ (MOU) ជាមួយធនាគារកណ្តាលរវ៉ាន់ដា ស្តីពី កិច្ចសហប្រតិបត្តិការក្នុងផ្នែកផ្សេងៗនៃការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ។ ពិធីចុះហត្ថលេខានេះធ្វើឡើងនៅរដ្ឋវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក ដោយលោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងឯកឧត្តម Rwangombwa John ទេសាភិបាលធនាគារកណ្តាលរវ៉ាន់ដា។

អនុស្សរណៈយោគយល់នេះ ធ្វើឡើងក្នុងគោលបំណង ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍលើផ្នែកនវានុវត្តន៍ហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ ព្រមទាំងដើម្បីចែករំលែកព័ត៌មាន និងចំណេះដឹងស្តីពីនវានុវត្តន៍ ការទូទាត់ឌីជីថលសម្រាប់សេវាហិរញ្ញវត្ថុ ការចែករំលែកចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជួយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ អនុស្សរណៈយោគយល់នេះ នឹងផ្តល់ជាក្របខណ្ឌជំរុញកិច្ចសហប្រតិបត្តិការ តាមរយៈការផ្លាស់ប្តូរចំណេះដឹង និងបទពិសោធន៍ដល់គ្នាទៅវិញទៅមក ព្រមទាំងនាំឱ្យស្ថាប័នទាំងពីរ ឈានដល់កិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុមួយកម្រិតទៀត ក្នុងការទាញយកផលប្រយោជន៍ពីការរីកចម្រើនផ្នែកបច្ចេកវិទ្យា ដើម្បីលើកកម្ពស់ការប្រើប្រាស់សេវាទូទាត់ជាអេឡិចត្រូនិករបស់ប្រជាជនក្នុងប្រទេសកម្ពុជានិងរវ៉ាន់ដា។ កិច្ចសហប្រតិបត្តិការនេះ នឹងរួមចំណែកយ៉ាងច្រើន ក្នុងការជំរុញសកម្មភាពធុរកិច្ច និងបរិយាបន្នហិរញ្ញវត្ថុរវាងប្រទេសទាំងពីរ។


**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖**
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA